# រឿងវិសមលោមរាជកុមារ

(ផលនៃការធ្វើទានដោយសេចក្តីជ្រះថ្លា)

កាល សាសនាព្រះសម្ពុទ្ធព្រះនាមកស្សប មានបុរសម្នាក់បានស្តាប់ធម៌ទេសនាព្រះសម្ពុទ្ធ មានសេចក្តីជ្រះថ្លាបានធ្វើទានប្រគេន ចង្ហាន់ចំពោះព្រះសង្ឃមានព្រះពុទ្ធជាប្រធាន លុះស្លាប់ទៅបានទៅកើតក្នុងសុគតិភព អស់កាលយូរអង្វែង ដល់មកសាសនាព្រះសម្ពុទ្ធគោតមបរមគ្រូរបស់យើងនេះ ព្រះអង្គបរិនិព្វានផុតទៅហើយ បានមកកើតជាព្រះរាជបុត្រព្រះបាទធម្មាសោករាជស្តេចចុល្លចក្រ មានរូបកាយល្អអស្ចារ្យ មានរោមក្រញាញ់ប្រទាក់គ្នា បានជាព្រះរាជបិតាព្រះរាជនាមថា វិសមលោមរាជកុមារ ដល់ចំរើនវ័យឡើងមានព្រះជន្ម ១៦ ព្រះវស្សា រូបរាងកាយក៏រឹតតែល្អមានកំលាំងខ្លាំងអស្ចារ្យ អាចហក់លោតទៅអាកាសបានកំពស់ ១៨ហត្ថ ។

ថ្ងៃមួយព្រះបាទធម្មាសោករាជបានប្រជុំព្រះរាជាចំនួន ប្រាំបីរយបួនពាន់អង្គដែលជាស្តេចចំណុះ លុះមកជួបជុំហើយក៏នាំទៅលេងព្រៃហេមពាន្ត ដើម្បីកំសាន្តសប្បាយ ឯវិសមលោមរាជកុមារ បានយាងទៅជាមួយដែរ ។

ព្រះបាទធម្មាសោកដែលមានស្តេច ប្រាំបីរយបួនពាន់អង្គ ចោមរោមជាបរិវារស្តេចយាងទៅដល់ស្ទឹងចន្ទភាគា ទ្រង់ឈប់សម្រាកនៅទីនោះ ។ ឯស្ទឹងចន្ទភាគានោះជាស្ទឹងធំ មានទទឹង ១ យោជន៍ ជម្រៅ ៣ គាវុត មានទឹកហូរខ្លាំងបែកពពុះធំៗ ជាស្ទឹងសម្បូណ៌ទៅដោយសត្វសាហាវគ្រប់មុខ ។

ព្រះបាទធម្មាសោក ទតឃើញស្ទឹងនោះគួរខ្លាច ហើយទ្រង់មានព្រះតម្រាស់ត្រាស់សួរពួកបរិវាទាំងអស់ថា អ្នកណាហ៊ានហែលកាត់ស្ទឹងនេះទេ ? ព្រះរាជាទាំង ប្រាំបីរយបួនពាន់អង្គ ដែលពូកែៗ ទាំងប៉ុន្មានមិនហ៊ានហែលឆ្លងឡើយ មានតែវិសមលោមរាជកុមារមួយចូលទៅថ្វាយបង្គំទូលថាហ៊ានហែលឆ្លង ។ ព្រះបិតាត្រាស់ថាបើឯងហ៊ានមែនហែលឆ្លងទៅ ! ហើយហែលមកវិញយើងចាំនៅទីនេះ ។

វិសមលោមកុមារ កាលបើព្រះរាជបិតាអនុញ្ញាតហើយ ក៏ផ្លាស់គ្រឿងអម្ពរទុកនៅសល់តែខោទ្រនាប់ខ្លី ថ្វាយបង្គំបិតាហើយហក់ពីមាត់ច្រាំងលើអាកាសបាន ១៨

ហត្ថ ទើបលោតចុះទៅក្នុងស្ទឹងហែលឆ្លងទៅត្រើយម្ខាង ហើយហែលត្រលប់មកវិញ មានសន្ទុះរហ័យដូចព្រួញ ពួកសត្វសាហាវទាំងឡាយមានក្រពើ ឆ្លាមជាដើមស្ទុះដេញខាំ វិសមលោមកុមារយកដៃទះបែកបាក់ខ្លួនប្រាណខ្ទេចខ្ទីជាច្រើន លុះមកដល់ហើយឡើងទៅថ្វាយបង្គំព្រះបិតា ៗ នឹកស្ងើចអស្ចារ្យក្រៃពេក ថាព្រះរាជបុត្រនេះមានឫទ្ធីច្រើនណាស់ គ្មានបុគ្គលណាស្មើឡើយ ឯស្ដេចទាំង ប្រាំរយបួនពាន់អង្គ ក៏អស្ចារ្យស្លុតព្រះទ័យ ។

គ្រាក្រោយមកព្រះរាជបិតានឹកខ្លាចថា ព្រះរាជបុត្រនឹងសម្លាប់អញយករាជសម្បត្តិបានដោយងាយ បើដូច្នេះអញត្រូវតែសម្លាប់ចោល លុះដល់ត្រឡប់មកនគរវិញ ក៏ប្រើរាជអមាត្យឲ្យចាប់វិសមលោមកុមារ ជាព្រះរាជបុត្រដាក់គុកបង្អត់បាយឲ្យតែបន្តិច ៗ កុំឲ្យឆ្លាប់ស្លាប់ ដល់គ្រប់៩ខែ ព្រះរាជាឲ្យអមាត្យចងឫស្សី ៦០បាច់ បង្កប់ដែកនៅខាងក្នុង ហើយតម្រៀបបញ្ឈរទុកក្នុងទីមួយទើបឲ្យទៅយកព្រះរាជបុត្រពីគុកមក ប្រាប់ថា ព្រះរាជបិតាឲ្យយកព្រះខ័នកាប់ឫស្សីទាំង ៦០បាច់ អោយដាច់ជាកំណាត់ប្រវែងបួនៗ ឆ្នាប់បើកាត់មិនដាច់ទេនឹងសម្លាប់ចោល ។

វិសមលោមកុមារប្រាប់រាជអមាត្យថា រកអាហារមកឲ្យខ្ញុំបរិភោគសិន ព្រោះ៩ខែហើយមិនដែលបានបរិភោគអាហារឲ្យឆ្អែតម្ដងទេ ។ រាជអមាត្យថាមិនបានទេ វិសមលោមកុមារនឹកក្នុងចិត្តថា បើបានអាហារបរិភោគឲ្យឆ្អែតអញនឹងកាប់ឫស្សីឲ្យដាច់ជាកំណាត់ៗ កុំឲ្យសល់ កំពុងតែគិតបណ្ដើរដើរបណ្ដើរ ក៏ឃើញស្រះមួយមានទឹកថ្លាល្អហើយសុំអមាត្យផឹក អមាត្យព្រមឲ្យផឹក ក៏ចុះទៅក្នុងស្រះមុជទៅកាយភក់ស៊ីដរាបដល់ឆ្អែត ទើបឡើងមកវិញទៅថ្វាយបង្គំព្រះរាជបិតា ៗ ថាបើឯងកាប់ឫស្សី ៦០បាច់នេះដាច់ដូចបង្គាប់មែន នឹងលើកលែងទោសឲ្យ បើកាត់មិនដាច់ទេយកទោសដល់ជីវិត ។ វិសមលោមកុមារទូលថាកាត់ដាច់ ទើបកាន់ព្រះខ័នហក់ស្ទុះទៅអាកាសកំពស់ ៨០ហត្ថ ចុះមកវិញកាប់ឫស្សីទាំង៦០បាច់ដាច់ជាកំណាត់ៗ ៤ៗផ្ទាប់ ហើយឮសូរកិណិៗ ដឹងថាគេបង្កប់ដែកនៅក្នុងក៏បោះព្រះខ័នចោលស្រែកទ្រហោយំ ។ វិសមលោមកុមារប្រាប់ថាខ្ញុំគ្មានអ្នកណាមួយស្រឡាញ់រាប់អានខ្ញុំ ទេ បើមានខ្លះមុខជាប្រាប់ថាឫស្សីនេះមានដែកនៅខាងក្នុងផង ខ្ញុំនឹងកាប់ដាច់ជាងនេះទៅទៀត ។

ព្រះរាជបិតាឮដូច្នោះហើយទ្រង់មានព្រះទ័យមេត្តា សោមនស្សចំពោះឥទ្ធិពល របស់ព្រះរាជបុត្រ ក៏ព្រះរាជទានសម្បត្តិជាច្រើនអភិសេកឲ្យឡើងឋានៈជាឧបរាជ ។ វិសមលោមកុមារកាលបើបានសុខស្រួលហើយ ក៏មានសទ្ធាជ្រះថ្លាចំពោះព្រះពុទ្ធសាសនា បានបរិច្ចាគទានរក្សាសីល ទំនុកបំរុងព្រះសង្ឃ មានព្រះមោគល្លីបុត្រតិស្សត្ថេរជាដើមដរាបដល់ទីបំផុតព្រះជន្ម ហោង ។

សូមអស់លោកអ្នកអនុមោទនា!

(ចប់)